# តើមូហាំម៉ាត់គឺជានរណា ?

## من هو محمد؟

صلى الله عليه وسلم



لجنة كمبوديا وفيتنام ولاوس التابعة
لجمعية الدعوة والإرشاد وتوعية
الجاليات في حي الصحافة
الرياض - المملكة العربية السعودية



រៀបរៀងដោយ


អង្គការវប្បធម៌ អារ្យធម៌កម្ពុជា អារ៉ាប់

Cambodia Arab Cultural Civilizational Organization

*អំពីព័ត៌មានបន្ថែម:*

អាស័យដ្ឋាន:ផ្ទះលេខ10អា ផ្លូវ បេតុង ភូមិទួលសំពៅ

សង្កាត់ ទួលសង្កែ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ

ប្រទេសកម្ពុជា

ទូរស័ព្ទលេខ:+85577997733 , +855962336659

Email:Cacco818140@gmail.com

# ព្យាការី មូហាំម៉ាត់

តើព្យាការីមូហាំម៉ាត់ជានរណា?

ព្រះជាម្ចាស់(អល់ឡោះ)មានបន្ទូលនៅក្នុងគម្ពីរគួរអានថា: "ជាការពិតណាស់ អ្នកទាំងអស់គ្នាមាន (មូហាំម៉ាត់) ជាអ្នកនាំសាររបស់ព្រះពិត(អល់ឡោះ)ជាគំរូល្អបំផុតសម្រាប់អ្នកដែលសង្ឃឹមថានឹង បានជួបទ្រង់ និងថ្ងៃបរលោក និងមានសសេចក្ដីនឹករលឹកច្រើនចំពោះទ្រង់"(គួរអាន33:21)។

សាសនិកឥស្លាមទូទៅ មានសេចក្ដីជំនឿថា មូហាំម៉ាត់ (សូមសន្តិភាពនិងពរជ័យមានមកដល់គាត់) គឺជា ព្យាការីចុងក្រោយបង្អស់ ក៏ដូចជាបណ្ដាព្យាការីនានាមុនគាត់ មានដូចជា ព្យាការី អាដាំ(Adam),ណូអេ(Noah),អាប្រាហាំ (Abraham), អ៊ីស្មាអែល(Ismael),អ៊ីសាក (Isaac), យ៉ាកុប(Jacob), យូ

សេហ្វ (Joseph), មូសេ(Moses), ដេវីដ ស (David), សូលូម៉ុង(Solomon),នឹងព្យាការីយេស៊ូ (សូមពរជ័យសន្តិភាពមានមកដល់គាត់) ។ ព្រះបាន បញ្ជូនបណ្តាព្យាការីខាងលើទាំងអស់នេះមក ដើម្បី អំពាវនាវមនុស្សលោក ឲ្យស្តាប់តាមឱវាទនិងធ្វើ សក្ការ:គោរពព្រះតែមួយអង្គគត់(អល់ឡោះ) ។ ព្រះ បាន បញ្ចុះគម្ពីរតូរ៉ា(Torah/ គម្ពីរដើមមិនទាន់គេកែ ប្រែ) មកឲ្យព្យាការីមូសេ(Moses),គម្ពីរគូស្បេល ឬ គម្ពីរបៃប៊ិល(Gospel/ គម្ពីរដើមមិនទាន់គេកែប្រែ ដូចនាបច្ចុប្បន្ន) បានបញ្ចុះមកឲ្យយេស៊ូ (Jesus) (សូមពរជ័យសន្តិភាពមានមកដល់គាត់) ក៏ ដូចគ្នាដែរ ព្រះបានបញ្ចុះគម្ពីរគួរអានមកឲ្យ ព្យាការីមូហាំម៉ាត់ ដើម្បីធ្វើសេចក្តី សំដែងឲ្យមនុស្សលោកទូទៅយល់ និង អនុវត្តតាមសេចក្តីប្រៀនប្រដៅតាមគម្ពីរគួរអាន។

មានថ្ងៃមួយនោះ គេបានសុំភរិយាព្យាការីមូ

ហាំម៉ាត់ (អាអុីសះ) ឲ្យពិពណ៌នា អំពីស្វាមីរបស់គាត់ (ព្យាការីមូហាំម៉ាត់) ខណៈនោះ អាអុីសះក៏បានឆ្លើយថា ស្វាមីរបស់គាត់ដើរតាមគម្ពីរគួរអាន។ មានន័យថា ព្យាការីមូហាំម៉ាត់ បានអនុវត្តតាមសេចក្តីបង្រៀនរបស់គម្ពីរគួរអានយ៉ាងល្អិតល្អន់ ជាទីបំផុតក្នុងឆាកជីវិតរបស់គាត់។

ដូច្នេះ យើងខ្ញុំ និងធ្វើការពន្យល់ អំពីសេចក្តីបង្រៀនដ៏ពិសិដ្ឋនេះ ឲ្យទៅជាសកម្មភាពថ្លៃថ្នូរផុតខ្ទោះជាទីបំផុតដូចតទៅនេះ :--

## 1.សេចក្តីមេត្តាករុណា

ព្រះជាម្ចាស់ (អល់ឡោះ) មានព្រះបន្ទូលនៅក្នុងគម្ពីរគួរអានថា ″ហើយយើងមិនបានបញ្ជូនអ្នកឡើយ (មូហាំម៉ាត់)លើកលែងតែដើម្បី ផ្តល់សេចក្តីមេត្តាករុណាទៅកាន់ពិភពលោកប៉ុណ្ណោះ″(គួរអាន21:107)។ ព្យាការីមូហាំម៉ាត់បានអំពាវនាវហៅមនុស្សលោកឲ្យ

ចេះថ្វាយបង្គំព្រះ អនុវត្តបួស និងឲ្យបរិច្ចាកទាន។ គាត់បានបង្រៀនមនុស្សជាតិ ឲ្យមានសេចក្តីជំនឿនិងព្រះ, សេចក្តីជំនឿនេះនឹងផ្តល់ឥរិយាបថល្អដល់អ្នកដទៃ។ ព្យាការីមូហាំម៉ាត់បានមានប្រសាសន៍ថា ″ អ្នកដែលល្អបំផុតក្នុងចំណោមនុស្សជាតិគឺជា អ្នកដែលមានចរិតល្អបំផុត″ ។ មានពាក្យសំដីជាច្រើនអំពីមូហាំម៉ាត់ (សូមពរជ័យសន្តិភាពមានមកដល់គាត់) បានផ្តោតសំខាន់ទៅលើទំនាក់ទំនងរវាងជំនឿ និងសកម្មភាព គឺសម្រាប់ឆ្លុះបញ្ចាំងជា ឧទាហរណ៍ស្រាប់ដូចព្យាការីបានមានប្រសាសន៍ថា ″ ជនណាហើយដែលមានជំនឿនិងព្រះ (អល់ឡោះ) និងថ្ងៃបរលោក ជននោះ មិនគួរបង្ករការឈឺចាប់ដល់អ្នកជិតខាងគេឡើយ, ជនណាហើយដែលមានជំនឿនិងព្រះ (អល់ឡោះ)និង ថ្ងៃបរលោក ជននោះគួរតែទទួលភ្ញៀវរបស់គេដោយ សេចក្តីសប្បុរសយ៉ាងរាក់ទាក់ជនណាហើយ

ដែលមានជំនឿនិងព្រះ(អល់ឡោះ) និងថ្ងៃបរលោក ជននោះគួរតែនិយាយល្អ បើមិនដូច្នោះទេ គួរនៅស្ងៀម"។

ការីចុងក្រោយ (មូហាំម៉ាត់) បា នបង្រៀនមនុស្សលោកទូទៅ ឲ្យចេះផ្ដល់សេចក្ដីមេត្តាករុណា និង ការគោរពសិទ្ធិគ្នាទៅវិញទៅមក ។ គាត់បានប្រសាសន៍ថា "អ្នកដែលគ្មានសេចក្ដីអាណិតស្រលាញ់ចំពោះអ្នកដទៃ ព្រះក៏គ្មានសេចក្ដីអាណិតស្រលាញ់ចំពោះជននោះដែរ"។មានសេចក្ដីរាយការណ៍មួយបានរាយការណ៍ថា: មានមនុស្សមួយចំនួនបានសំណូមពរព្យាការី(មូហាំម៉ាត់) ឲ្យព្យាការីបួងសួងសុំព្រះជាម្ចាស់ឲ្យទ្រង់បញ្ជូនទណ្ឌកម្មដល់អ្នកគ្មានជំនឿនិងទ្រង់ ប៉ុន្តែព្យាការីបានឆ្លើយតបថា"ព្រះមិនបានបញ្ជូនខ្ញុំ មកដើម្បីជាបណ្ដាសាទៅដល់មនុស្សលោកទេ តែដើម្បីសេចក្ដីមេត្តាករុណាទៅវិញ"។

## 2.ការអភ័យទោស

ព្រះ(អល់ឡោះ)មានព្រះបន្ទូលថា៉"ចូរឲ្យពួកគេបេះអភ័យទោស និងអធ្យាស្រ័យឲ្យគ្នា,តើអ្នកទាំងអស់គ្នាមិនប្រាថ្នាចង់ឲ្យព្រះ(អល់ឡោះ) អភ័យទោសដល់អ្នកទាំងអស់គ្នាទេឬ?"(គួរអាន24:22)។ ព្យាការីមូហាំម៉ាត់ គឺជាមនុស្សមហាសែនអភ័យទោស និងចិត្តល្អបំផុតចំពោះមនុស្សជាតិ។ នៅពេលមានអ្នកណាម្នាក់រំលោភបំពាន ឬធ្វើបាបគាត់ គាត់អភ័យទោសឲ្យជននោះជានិច្ច។ បើមានអំពើហិង្សាមកលើគាត់កាន់តែខ្លាំង គាត់បន្ថែមអំនត់អត់ធ្មត់កាន់តែច្រើន។ គាត់ជាមនុស្សមានការអត់អោន និង ការអភ័យទោសជាទីបំផុត, មិនតែប៉ុននោះ គាត់មិនដែលធ្វើការសងសឹកទៅលើជនណាឡើយ ជាពិសេសនៅពេលអំណាចទាំងមូល ស្ថិតក្នុងកណ្តាប់ដៃរបស់គាត់។ព្យាការីមូហាំម៉ាត់ (សូមពរជ័យសន្តិភាពមានមកដល់គាត់)

អភ័យទោសទាំងអស់ ឬរាប់មិនអស់ចំពោះជនទាំងឡាយ ណាដែលធ្លាប់បានរំលោភបំពានឬធ្វើទុកបុកម្នេញប្រឆាំងគាត់។ នេះសបញ្ជាក់ថា ព្យាការីមូហាំម៉ាត់ពិតជាគំរូដ៏ល្អបំផុត ចំពោះការអភ័យទោស និងសេចក្ដីមេត្តាករុណា សម្រាប់ មនុស្សជាតិទូទៅ ដូចព្រះ (អល់ឡោះ) មានព្រះបន្ទូលថា″ចូរអ្នក (មូហាំម៉ាត់) ទទួលយកការអធ្យាស្រ័យ និងប្រើគ្នាឲ្យធ្វើអំពើល្អ និងជៀសចេញឲ្យឆ្ងាយអំពីទង្វើអវិជ្ជាឬភាពល្ងង់ខ្លៅ″(គួរអាន7:199)។

3. **សមភាព**: ព្រះ(អល់ឡោះ)មានព្រះបន្ទូលថា‟ពិតប្រាកដណាស់ អ្នកដែលមានភាពថ្កុំថ្កើងជាងគេបំផុត គឺជាអ្នកដែលត្រឹមត្រូវជាងគេបំផុតចំពោះព្រះ ″ (គួរអាន49:13)។ ខាងក្រោមនេះជាទ្រឹស្ដីរបស់ព្យាការីមូហាំម៉ាត់បង្រៀនថា មនុស្សជាតិទាំងអស់គឺ មានសិទ្ធិស្មើៗគ្នាចំពោះព្រះ: ‟មនុស្សជាតិ

ទាំងអស់ មានដើមកំណើតពីអាដាំ(Adam)ហើយអាដាំ(ព្រះបង្កើត)ចេញពីដីឥដ្ឋ។ ប្រជាជាតិអារ៉ាប់មិនមែនមានឧត្តមភាពជាងប្រជាជាតិផ្សេងៗ។ មិនមែនជនជាតិស្បែកខ្មៅប្រសើរជាងស្បែកស លើកលែងតែអ្នកដែលដើរតាមគន្លងធម៌ព្រះ"។ ព្យាការីក៏ពោលបន្តទៀតថា: "ព្រះមិនបានវិនិច្ឆ័យ (អំពើល្អ) ទៅលើអ្នកទាំងអស់គ្នា ដោយផ្តោតសំខាន់លើរូបរាងខាងក្រៅនិងទ្រព្យសម្បត្តិរបស់អ្នកទេ តែជាតុពិតទ្រង់ត្រួតពិនិត្យមើលដួងចិត្ត និងទង្វើរបស់អ្នកទាំអស់គ្នា"។ មានពេលមួយមានបុរសម្នាក់ បានហៅឈ្មោះបុរសម្នាក់ផ្សេងទៀត ដោយពាក្យសម្តីមិនសមរម្យគឺ"ហេ!អាកូនស្រីខ្មៅ"។ លឺដូច្នេះ ព្យាការី (សូមពរជ័យសន្តិភាពមានមកដល់គាត់)មានអារម្មណ៍ខឹង ហើយក៏បាននិយាយទៅកាន់បុរសនោះថា " តើអ្នកបន្ទោសបុរសនោះ ព្រោះតែម្តាយរបស់គាត់ខ្មៅរឺ?នេះ អ្នកនៅតែមានសារជាតិ

អវិជ្ជាពីមនុស្សល្ងង់ខ្លៅសម័យកាលមុនឥស្លាមដដែល”

### 4. ភាពអត់ឱន

ព្រះបានមានបន្ទូលថា “អំពើល្អនិងអំពើអាក្រក់គឺមិនអាចស្មើគ្នាបានឡើយ, ចូរអ្នក(មូហាំម៉ាត់)ច្រានចោលទាំងអស់នូវអំពើអសីលធម៌ទាំងឡាយ ដោយឆ្លើយតបទៅវិញនូវអំពើល្អបំផុត ពេលនោះសត្រូវរបស់អ្នកនឹងក្លាយ ជាមិត្តជិតស្និទ្ធរបស់អ្នកជាមិនខាន” (គួរអាន41:34)។ព្យាការីមូហាំម៉ាត់បានទូន្មានថា”អ្នកមិនគួរធ្វើអំពើអាក្រក់ ទៅកាន់អ្នកដែលធ្វើអំពើអាក្រក់មកលើអ្នកទេ ប៉ុន្តែអ្នកគួរតែដោះស្រាយជាមួយអ្នកទាំងនោះ ដោយសេចក្តី អភ័យទោសនិងធ្វើល្អ”។ ខាងលើ នេះជាសេចក្តីទូន្មានរបស់ព្យាការីចុងក្រោយ (សូមពរជ័យសន្តិភាពមានមកដល់គាត់) បានឆ្លើយតបទៅចំពោះអ្នកដែលរំលោភបំពាននិងបញ្ឈឺគាត់។ ពត៌មានចេញពីបណ្តាប្រភពឥស្លាមបានរាយការណ៍ថា: ព្យា

ការី (ក្នុងសម័យកាលគាត់) មានឱកាសយ៉ាងច្រើនក្នុងការឆ្លើយតបសងសឹកភ្លាមៗ ទៅដល់អ្នកដែលធ្វើខុសចំពោះគាត់ ប៉ុន្តែព្យាការីទប់ស្កាត់មិនឲ្យអំពើនោះកើតមានឡើងឡើយ។ លើសពីនេះទៅទៀត ព្យាការីបានបង្រៀនមនុស្សជាតិ ឲ្យចេះអត់ធ្មត់និងភាពលំបាកនិងឧបសគ្គដែលខ្លួនកំពុងប្រឈមមុខ ដូចគាត់បានមានប្រសាសន៍ថា: ″ អ្នកដែលខ្លាំងមិនមែនអ្នកដែលយកឈ្នះមនុស្ស ដោយប្រើកម្លាំងខ្លាំងរបស់គាត់នោះទេ តាមពិតអ្នកដែលខ្លាំងនោះ គឺជាអ្នកដែលមានសមត្ថភាពគ្រប់គ្រងកំហឹងរបស់ខ្លួនឯងបាន នៅពេលខ្លួនមានកំហឹង″។

ការអនុវត្តន្ទូវ សេចក្តីអត់ធ្មត់និងសេចក្តីអត់អោន មិនមែនមានន័យថា ឲ្យសាសនិកឥស្លាម (មូស្លីម) អសកម្ម និងមិនឲ្យការពារខ្លួនឯង ប្រឆាំងនិងការវាយប្រហារនោះទេ។ព្យាការីមូហាំម៉ាត់បានមានប្រសាសន៍

ថា "ចូរអ្នកកុំប្រាថ្នាជួបនឹងសត្រូវឲ្យសោះ ប៉ុន្តែនៅពេលអ្នកជួបសត្រូវ សូមអ្នកអត់ធ្មត់ (រឹងមាំនៅពេលជួបសត្រូវ) ។

## 5. សុភាពរាបសា

មានមិត្តជិតស្និទ្ធម្នាក់ របស់ព្យាការីមូហាំម៉ាត់ ដែលបានមើលថែរក្សាព្យាការី អស់រយៈពេលជាង១០ ឆ្នាំ បានអះអាងថា:មូហាំម៉ាត់ (សូមពរជ័យសន្តិភាពមានមកដល់គាត់) ជានិច្ចកាលជាមនុស្សសុភាពរាបសារក្នុងសកម្មភាពរបស់គាត់។ អ្នកថែរក្សាព្យាការីបានពោលបន្តទៀតថា" នៅពេលខ្ញុំធ្វើអ្វីមួយ គាត់មិនដែសួរដេញដោលខ្ញុំទេ។ នៅពេលខ្ញុំមិនបានធ្វើការ គាត់ក៏មិនប្រើខ្ញុំឲ្យធ្វើការដែរ គាត់ជាមនុស្សស្លូតបូតបំផុត"។ មានពេលមួយនោះ ភរិយារបស់ព្យាការីមានការខឹងសម្បាយ៉ាងខ្លាំង ដោយទទួលរងនូវការប្រមាថពីបុគ្គលម្នាក់។ ពេលនោះព្យាការីក៏បានទូន្មានភរិយា

របស់គាត់(អាអ៊ីសា)ថា:″ អាអ៊ីសះអើយ!សូមធ្វើខ្លួនឲ្យទន់ភ្លន់ និងកុំឆេវឆាវ ពីព្រោះព្រះ (អល់ឡោះ) ចូលចិត្តភាពសុភាពរាបសារ ឬ ភាពទន់ភ្លន់រាល់គ្រប់កិច្ចការទាំងអស់″។ ព្យាការីបាន ប្រសាសន៍ទៀតថា ″ចូរអ្នកបង្ហាញភាពទន់ភ្លន់ ! ពីព្រោះភាពទន់ភ្លន់នេះហើយ និង ធ្វើឲ្យអ្វីៗមួយចំនួនមានសោភ័ណភាព ហើយនៅពេលភាពទន់ភ្លន់នោះបាត់បង់ពីរបស់នោះ វានិងធ្វើឲ្យរបស់នោះខ្វះរូបរាង។

## 6. ការបន្ទាបខ្លួន

ព្រះ (អលឡោះ) មានព្រះបន្ទូលថា "ហើយបណ្តាខ្ញុំ(ល្អត្រឹមត្រូវ) នៃព្រះមហាសប្បុរស(អល់ឡោះ) គឺនៅពេលពួកគេ (ខ្ញុំរបស់ទ្រង់) ធ្វើដំណើរនៅលើផែនដីគឺពួកគេពោរពេញទៅដោយ កាយវិការសុភាពរាបសា ហើយនៅពេលអ្នកគ្មាន សីលធម៌និយាយស្តីទៅកាន់គាត់ គាត់នៅតែឆ្លើយតបនិងអ្នក

គ្មានសីលធម៌ នោះដោយសម្ដីយ៉ាងសន្តិភាព"(គួរអាន 25:63)។ ព្យាការី(សូមពរជ័យសន្តិភាពមានមកដល់គាត់) ធ្លាប់ហាមឃាត់មនុស្សមិនឲ្យក្រោកឈរ ដើម្បីសំដែងការគោរពដល់គាត់។ នៅក្នុងអង្គប្រជុំឬកន្លែងប្រជុំ ព្យាការីមិនដែលប្រកាន់យកកន្លែងអង្គុយដែលមានលក្ខណ:ល្អ និងខ្ពស់ជាងគេទេ ហើយមិនដែលចាត់ទុករឿងនោះ ជារឿងសំខាន់ទេ គឺគាត់អង្គុយកន្លែងណាដែលមនុស្សអាចអង្គុយបាន ។ មិនតែប៉ុណ្ណោះ គាត់មិនដែលពាក់ខោអាវបង្ហាញពីឋានន្តរសក្តិ បែងចែកខ្លួនគាត់និងមិត្តភក្តិដែលជាអង្គប្រជុំជាមួយគាត់ ដើម្បីសម្គាល់ថាគាត់មានឋាន:ខ្ពស់ជាងគេ ទាំងអស់នោះទេ។ គាត់បានអង្គុយលេងនឹងអ្នកក្រ អ្នកក្រខ្សត់ មនុស្សចាស់ និងបានជួយឧបត្ថមចំពោះស្រីមេម៉ាយ។ នៅកន្លែងសាធារណ:ពេលខ្លះមនុស្សខ្លះនៅក្នុងចំណោមហ្វូងមនុស្សទាំងអស់នោះ

មិនបានស្គាល់ព្យាការីទេ។ ព្យាការីបានឲ្យដំបូន្មានដល់បណ្ដាមិត្តភក្តិរបស់គាត់ថា៉ព្រះបានបញ្ជូនសារមកឲ្យខ្ញុំថា អ្នកត្រូវបន្ទាបខ្លួន មិនត្រូវមានអំនួត និងមិនត្រូវជិះជាន់ទៅលើអ្នកដទៃ៉។ ដោយសេចក្តីសុភាពរាបសាដូច្នោះហើយ ដែលធ្វើឲ្យព្យាការី ខ្លាចមានមនុស្សគោរពបូជាគាត់។ការគោរពបូជាសក្ការៈ គឺជាឯកសិទ្ធិសម្រាប់តែព្រះតែមួយអង្គគត់(អល់ឡោះ)។

ព្យាការីបានផ្តាំផ្ញើរ មកកាន់យើងទាំងអស់គ្នាដែលជាមនុស្សជាតិថា "ចូរអ្នកកុំធ្វើឲ្យហួសខ្នាតក្នុងការលើកតម្កើងខ្ញុំ ដូចនិងអ្វីៗដែលគ្រិស្តបរិស័ទបានលើកតម្កើងដល់យេស៊ូ(Jesus)កូនប្រុសម៉ារីឲ្យសោះពីព្រោះខ្ញុំគ្រាន់តែជាខ្ញុំបម្រើរបស់ព្រះ,ដូច្នេះ ចូរអ្នកទាំងអស់គ្នាហៅខ្ញុំថាៈ (មូហាំម៉ាត់)គឺជាខ្ញុំបម្រើរបស់ព្រះ និងជាអ្នកនាំសាររបស់ទ្រង់៉។

## 7.ជាស្វាមីល្អ

ព្យាការី (សូមសន្តិភាពមានមកដល់គាត់) ស្រលាញ់ភរិយារបស់គាត់ណាស់។ ពេលមួយនោះ អាអ៊ីស៊ះ (ភរិយារបស់មូហាំម៉ាត់) បានរៀបរាប់ប្រាប់គេអំពីស្វាមីប្រកបដោយភាពថ្លៃថ្នូររបស់គាត់ថា ″ គាត់ជានិច្ចកាលជួយការងារផ្ទះ។ ពេលខ្លះគាត់ប៉ះខោអាវជួសជុលស្បែកជើងរបស់គាត់និងបោសសំអាតផ្ទះ ។ គាត់ក៏បានប្រចាប់យកទឹកដោះសត្វ ថែរក្សានិងចិញ្ចឹមសត្វរបស់គាត់ និងធ្វើការងារផ្ទះ″។ ព្យាការីមិនត្រឹមតែជាស្វាមីមានភាពស្មោះត្រង់ គួរឲ្យស្រលាញ់សម្រាប់ភរិយារបស់គាត់ប៉ុណ្ណោះទេ គាត់ថែមទាំង បានជម្រុញអ្នកនៅជុំវិញគាត់ឲ្យយកគំរូតាមគាត់។ គាត់បានមានប្រសាសន៍ថា″អ្នកដែលមានភាពល្អឥតខ្ចោះនៃអ្នកដែលមានជំនឿនិងព្រះនោះ គឺជាអ្នកដែលមានសីលធម៌ល្អឥតខ្ចោះបំផុត ហើយនៅក្នុងចំណោមមនុស្សល្អ

ឥតខ្ចោះបំផុតនោះ គឺជាអ្នកដែលល្អបំផុតចំពោះភរិយារបស់ខ្លួន៉។

**8.ជាគំរូល្អឥតខ្ចោះសម្រាប់មនុស្សជាតិ**

ព្រះ(អល់ឡោះ) បានមានព្រះបន្ទូលថា"ពិតណាស់(មូហាំម៉ាត់) អ្នកពិតជាមានអត្តចរិតដ៏ប្រពៃបំផុត(គួរអាន68:4)។ អ្វីដែលបានលើកមកពិពណ៌នានៅទំព័រមុននេះបន្តិច គឺគ្រាន់តែជាឧទាហរណ៍តិចតួចបំផុតដែលឆ្លុះបញ្ចាំងអំពីជីវិតរបស់ព្យាការីមូហាំម៉ាត់។ ពល់គំរូរបស់ព្យាការី ដែលបង្ហាញអំពីអំពើល្អ និងភាពមេត្តាករុណារបស់គាត់ខ្លះៗនេះ អាចនឹងធ្វើឲ្យអ្នកដែលលាបពណ៌អាក្រក់មកលើសាសនាឥស្លាមតាមបណ្តាញសារពត៌មាននានា ឲ្យមានការភ្ញាក់រលឹកចំពោះការបកស្រាយដែលមិនត្រឹមត្រូវរបស់ខ្លួនជាបន្តបន្ទាប់នាពេលបច្ចុប្បន្ន។នៅពេលយើងព្យាយាមចង់ ស្វែងយល់អំពីសាសនាឥស្លាម វាជាការងាយស្រួលនិងមាន

សារសំខាន់បំផុត គ្រាន់តែយើងធ្វើការទំនាក់ទំនងដោយផ្ទាល់ ទៅរកប្រភពរបស់ឥស្លាម គឺគម្ពីរគួរអាន និងរាល់ពាក្យសំដីរបស់ព្យាការីមូហាំម៉ាត់ និងរាល់សកម្មភាពរបស់គាត់។ ដូច្នេះយើងមិនគួរវិនិច្ឆ័យសាសនាឥស្លាមដោយផ្អែកមើល លើសកម្មភាពខុសឆ្គង របស់សាសនិកឥស្លាមតែមួយក្រុមតូចនោះទេ តែយើងគួរតែសិក្សានិងស្វែងយល់តាម ការអប់រំត្រឹមត្រូវដែលមានប្រភពពិតចេញពីគម្ពីរគួរអាន និងរាល់ពាក្យសំដីរបស់ព្យាការីមូហាំម៉ាត់ និង រាល់សកម្មភាពរបស់គាត់ ទើបជាការត្រឹមត្រូវសុក្រិតល្អឥតខ្ចោះជាទីបំផុត។

**សេចក្តីអត្ថាធិប្បាយរបស់បុគ្គលល្បីៗមិនមែនឥស្លាមលើព្យាការីមូហាំម៉ាត់**

☞លោក មហាត្មៈគន្ធី (Mahatma K Gandhi / ដែលជាអ្នកដឹកនាំសាសនានិងនយោបាយដ៏ល្បី នៃចលនាទាមទារឯករាជ្យភាពឥណ្ឌាបានមានប្រសាសន៍

ថា (ព្យាការីមូហាំម៉ាត់ពិតជាមនុស្ស មានភាពសាម ញ្ញៗយ៉ាងខ្លាំងនិងជាមនុស្សមានភាពឱនលំទោនជាទី បំផុត ហើយខ្ញុំគិតថាព្យាការីពិតជាមនុស្សគោរពពាក្យ សន្យា ទៀងត្រង់បំផុត និង ជាមនុស្សមានភក្តីភាព អស់ពីដួងចិត្តចំពោះបណ្តាមិត្តភក្តិ និងអ្នកតាមគាត់ ទាំងឡាយ។ ភាពក្លាហាន មិនចុះញម ការជឿព្រះអស់ ពីចិត្ត បូករួមនិងសកម្មភាពផ្ទាល់ខ្លួនរបស់គាត់ទាំង អស់នេះហើយដែលធ្វើឲ្យគាត់បាន ជំនះរាល់ឧបសគ្គ ទាំងអស់ដោយមិនបាច់ប្រើអាវុធ (ដាវ) យកមកដោះ ស្រាយចំពោះមុខ)។

☞លោក ជច បឺណាត ស្ស(George Bernard Shaw/1856-1950)ជាអ្នកនិពន្ធសរសេររឿងភាពយន្ត និង ជាសកម្មជននយោបាយដ៏ល្បីមួយរូបរបស់ជន ជាតិអង់គ្លេស បានធ្វើសេចក្តីថ្លែងការណ៍អំពីរឿងព្យា ការីមូហាំម៉ាត់មានដូចតទៅ:″ពិភពលោកពិតជាត្រូវការ

មនុស្សដែលមាន សតិបញ្ញាញាណដូចមូហាំម៉ាត់យ៉ាង ចាំបាច់ជាទីបំផុត។ នៅពាក់កណ្ដាលនៃយុគសម័យ កាល ដោយសារតែភាពអវិជ្ជា និងការប្រកាន់ពូជ សាសន៍របស់ខ្លួន អ្នកកាន់សាសនា(ផ្សេងពីឥស្លាម) បានលាបពណ៌យ៉ាងខ្មៅងងឹតដល់ព្យាការី ដោយសារ តែពួកគេធ្លាប់គិតថា មូហាំម៉ាត់ជា សត្រូវរបស់អ្នកកាន់ សាសនាគ្រិស្ដ ប៉ុន្ដែក្រោយពីខ្ញុំបានពិនិត្យមើលរឿង ពិតអំពីគាត់រួច ខ្ញុំបានរកឃើញថា គាត់(មូហាមម៉ាត់) គឺជាមនុស្សពោរពេញ ដោយអច្ឆរិយៈអស្ចារ្យគួរឲ្យងឿ យឆ្ងល់ជាទីបំផុត ហើយចុងបញ្ចប់សេចក្ដីរបស់ខ្ញុំ ខ្ញុំ អាចនិយាយថាគាត់(មូហាំម៉ាត់) មិនអាចជាសត្រូវ របស់គ្រិស្ដសាសនិកជាដាច់ខាត ហើយត្រូវតែហៅគាត់ ថា ជាអ្នកសង្គ្រោះមនុស្សជាតិ។ នៅក្នុងទស្សនៈរបស់ ខ្ញុំ ខ្ញុំយល់ថាប្រសិនជាបច្ចុប្បន្ននេះមានគាត់មកដឹកនាំ ពិភពលោក នោះគាត់ និង មានដំណោះស្រាយបញ្ហារ

រួមរបស់យើង និង ជានានូវសន្តិភាពនិងសុភមង្គល ដែលពិភពលោកកំពុងចង់បានយ៉ាងខ្លាំង″។

***<u>សម្រាប់រាល់ឯកសារបន្ថែមអំពីឥស្លាម:</u>***

- *អាចជជែក(chat)តាមអនឡាញwww.islamtomorrow.com/*
- *ទាញយកជាវេឌីអូ:www.thedeenshow.com*
- *ទាញជាសៀវភៅ:www.islamic-message.net/cims/default.aspx*
- *អំពីព្យាការីមូហាំម៉ាត់:www.rasoulallah.net*

# ព្យាការីមូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះ

لجنة كمبوديا وفيتنام ولاوس التابعة لجمعية الدعوة
والإرشاد وتوعية الجاليات في حي الصحافة
الرياض - المملكة العربية السعودية